គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល COMFREL



គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក យឹម ប៉ូ
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា ស៊ុន ចាន់សែន
Miss. SUN Chansen
ប្រធាន KYA

លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

លោកស្រី ពឹង យក់ហៀប
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី ទិវ សារាយេត
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា សាយ សារ៉ា វឌ្ឍនី
Miss. SAY Sara Vathany
នាយិកា CWCC

លោក គីម សុវណ្ណ
Mr. KIM Sovann
នាយក VIGILANCE

លោក អាង ច័ន្ទឫទ្ធិ
Mr. ANG Chanrith
នាយក KKKHRO

លោក យង់ គិមអេង
Mr. YONG Kim Eng
នាយក PDP-Center

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សឺន សែត
Mr. SEN Set


ស.ប្រ.ក.៣/លេខ ១៤/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត សៀមរាប

*ភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨២នាក់ មកពីស្រុកផ្សេងៗគ្នាក្នុងខេត្តសៀមរាប ក្នុងនោះមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ៤៧% បានជួបជុំគ្នានៅក្នុងសិក្ខាសាលា ម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្ត សៀមរាបកាលពីចុងខែកក្កដា ២០០៩ ដើម្បីពិភាក្សា និងកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តសៀមរាប កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៩។

អភិបាលរងខេត្តសៀមរាប លោកជំទាវ **ឯម ផល្លាមុនី** បានថ្លែងបើកសិក្ខាសាលាថា រាជរដ្ឋាភិបាលអាណត្តិទី ៤ បានដាក់ចេញ នូវយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌ និងកំណែទំរង់ទាំងឡាយដែលជាការចាំបាច់បំផុតសំរាប់ធានាបាននូវប្រសិទ្ធភាពខ្ពស់ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា។ លោកជំទាវក៏បានជំរុញអោយប្រជាពលរដ្ឋចូលរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីអោយការអនុវត្តបានទទួលជោគជ័យ ។

អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** មណ្ឌលសៀមរាប និងសមាជិកក្រុមប្រឹក្សាខេត្តសៀមរាប ឯកឧត្តម **កុយ សង** មកពីគណបក្សប្រជាជន និងឯកឧត្តម **សុខ គីមសេង** សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប មកពីគណបក្សសមរង្ស៊ី ដែលបានទទួលលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ សំរាប់ខេត្តសៀមរាបដោយផ្ទាល់ដៃ បានទទួលស្គាល់ថាអ្វីដែលប្រជាពលរដ្ឋបានលើកឡើងគឺពិតជាតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋហើយបានសន្យាថា នឹងជំរុញអោយរាជរដ្ឋាភិបាលអនុវត្តលក្ខខណ្ឌសន្ទស្សន៍នៃ វិស័យអាទិភាពទាំងនេះហើយនឹងពាំនាំអ្វីដែលប្រជាជនលើកឡើងជូនរាជរដ្ឋាភិបាល។

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប **កែ សុវណ្ណរតន៍** *"បានសន្យាថានឹងត្រៀមខ្លួនដោះស្រាយ ជាពិសេសគាំទ្រនូវសំណើទាំង១០នេះ"*។ ចំណែក ឯកឧត្តម **កុយ សង** បានមានប្រសាសន៍ថា *"សំណើរទាំងអស់ដែលប្រជាពលរដ្ឋបានលើកឡើងក៏មាននៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។"*

ជាលទ្ធផល ម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ក្នុងខេត្តសៀមរាបដូចខាងក្រោមៈ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តសៀមរាបរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០នៅក្នុងខេត្ត សៀមរាប** |
|---|
| ១) ជំរុញអោយរាជរដ្ឋាភិបាល និងសភាអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយអោយបានឆាប់រហ័សនៅដើមឆ្នាំ ២០១០។ ត្រូវអនុវត្តអោយបានត្រឹមត្រូវ និងតម្លាភាព [តាមច្បាប់កំណត់] ព្រមទាំងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អោយបានទូលំទូលាយ ទូទាំងប្រទេស ។ |
| ២) - ជួយផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ៤ វគ្គ ក្នុង មួយឆ្នាំ ក្នុងមួយស្រុកអោយបាននៅគ្រប់ស្រុកដើម្បីអោយទិន្នផលពី ១តោន ដល់ ៣តោន ក្នុង ១ហិកតា ចាប់ពីដើមឆ្នាំ ២០១០នេះតទៅ។<br>- សុំផ្តល់ទុនកម្ចីដោយមានអត្រាការប្រាក់ទាប ប្រហែល ២ ភាគរយក្នុងមួយឆ្នាំ សំរាប់ការងារកសិកម្ម នៅខេត្តសៀមរាបចាប់ពីដើមឆ្នាំ ២០១០ តទៅ។<br>- ជួយរកទីផ្សារ បង្កើនតំលៃស្រូវ ១ គីឡូក្រាមយ៉ាងហោចណាស់ស្មើមួយភាគបីនៃ តំលៃប្រេងសាំង ក្នុង ១ លីត្រ អោយបាន នៅដើមឆ្នាំ ២០១០។ |
| ៣) ត្រូវទប់ស្កាត់ផលិតផលក្រៅស្រុក កុំអោយចូលមកខេត្តសៀមរាប មាន មាន់ ទា ត្រី ចាប់ពីឆ្នាំ ២០១០ ។ លុបបំបាត់ឧបករណ៍នេសាទខុសច្បាប់អោយបាន [១០០ ភាគរយ] ចាប់ពី ខែ ១០ ឆ្នាំ ២០០៩តទៅ ។ |
| ៤) ផ្តល់ដីសម្បទានសង្គមកិច្ចដល់អ្នកក្រីក្រខ្វះដីពិតប្រាកដ មួយគ្រួសារអោយបាន ៣ ហិកតា នៅខេត្តសៀមរាប អោយបាននៅដើមឆ្នាំ ២០១០ ។ |
| ៥) សុំតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការព្រមទាំងកងកំលាំងប្រដាប់អាវុធអោយបានយ៉ាងតិច ១៥០ ដុល្លារក្នុងមួយខែ ឡើងទៅ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៦) កំណែទំរង់ប្រព័ន្ធតុលាការអោយមានភាពឯករាជ្យ អព្យាក្រឹត និងយុត្តិធម៌ ១០០ ភាគរយ ចាប់ពីដើមឆ្នាំ ២០១០។ |
| ៧) សុំអោយចាត់វិធានការតំលៃអគ្គិសនីនៅខេត្តសៀមរាបដោយ ១ គីឡូវ៉ាត់ ស្មើ ១ ភាគ ៤ នៃតំលៃប្រេងសាំង ចាប់ពីឆ្នាំ ២០១០។ |
| ៨) ផ្តល់សំណងថ្លៃដីនៅស្រុកវ៉ារិន្ទអោយបានសមរម្យ (តាមតំលៃទីផ្សារ) ដែលអាចទិញដីកន្លែងក្បែរៗនោះបាន ចាប់ពីឆ្នាំ ២០១០ និងបញ្ឈប់ការប្រើប្រាស់កំលាំងប្រដាប់អាវុធទៅគំរាមប្រជាពលរដ្ឋក្នុងខេត្តសៀមរាបចាប់ពីឆ្នាំ ២០០៩ តទៅ។ |
| ៩) សុំអោយអាជ្ញាធរអប្សរាដោះដូរដីស្រែ (ដីកន្លែងថ្មីដែលនៅជិតភូមិប្រជាពលរដ្ឋ) អាចបង្កបង្កើនផលបានចាប់ពីឆ្នាំ ២០១០។ ស្នើសុំអោយបញ្ឈប់ការដកហូតដីស្រែដែលនៅសល់របស់ប្រជាពលរដ្ឋបន្តទៅទៀតនៅក្នុងតំបន់អប្សរា ចាប់ពីខែ សីហា ឆ្នាំ ២០០៩ នេះតទៅ។ |
| ១០) លុបបំបាត់សេវាបំរើផ្លូវភេទគ្រប់រូបភាពអោយបាន ១០០ ភាគរយ នៅក្នុងខេត្តសៀមរាប ចាប់ពីដើមឆ្នាំ ២០១០ នេះតទៅ។ |

សិក្ខាសាលានេះត្រូវបានរៀបចំដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយសមាគមការពារសិទ្ធមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) និងអង្គការសហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (PADEK) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោតមកពីស្រុកក្រឡាញ់ ស្រុកសូត្រនិគម ស្រុកពួក ស្រុកអង្គរជុំ ស្រុកអង្គរធំ និងក្រុងសៀមរាប នៅក្នុងខេត្តសៀមរាប

ដែលតំណាងឱ្យសហគមន៍នេសាទ ព្រៃឈើ ដីធ្លី... និងអង្គការមិនមែន រដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/ គណៈអភិបាលខេត្ត រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ច័ន្ទ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិន្ទុរៀ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦